E5/10/1

[០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ]

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**សំណុំរឿងលេខ៖** ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ដាក់តម្កល់ជូន៖** អង្គជំនុំជម្រះសាលាដំបូង

**កាលបរិច្ឆេទដាក់ឯកសារ៖** ១៦ កុម្ភៈ ២០០៩

**ភាគីអ្នកតម្កល់៖** មេធាវីរបស់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច

**ភាសាដើម៖** ភាសាបារាំង

**ប្រភេទឯកសារ៖** សាធារណៈ

---

## ចម្លើយរបស់ក្រុមការពារក្តីចំពោះសំណើរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ សំដៅដាក់ធាតុភស្តុតាងថ្មីៗ

---

<u>បញ្ជូនដោយ៖</u>

**មេធាវីរបស់ជនជាប់ចោទ**

**លោក កាំង ហ្គេកអ៊ាវ**

លោក ការ សាវុត្ថ

លោក François ROUX

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 02 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

<u>បញ្ជូនទៅ៖</u>

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង**

លោកចៅក្រម និល ណុន (ប្រធាន)

លោកស្រីចៅក្រម Silvia CARTWRIGHT

លោកចៅក្រម យ៉ា សុខន

លោកចៅក្រម Jean-Marc LAVERGNE

លោកចៅក្រម ធូ មណី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក គង់ ពិសី

លោក ហុង គីមសួន

លោក យ៉ុង ផានិត

លោកស្រី Silke STUDZINSKY

លោក គីម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

E5/10/1

[00១/១៨-0៧-២00៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.0២)]

លោក Martine JACQUIN

លោក Philippe CANNONE

កញ្ញា ទ្រី ស្រ៊ុនណា

លោក Pierre Olivier SUR

00281813

E5/110/1

[០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ]

# ជូនចំពោះអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង នូវសំណើមួយសំដៅដាក់ធាតុភស្តុតាងថ្មីៗ គឺខ្សែភាពយន្តចំនួនពីរឈុតដែលបង្ហាញអំពីរូបភាពរបស់មន្ទីរសន្តិសុខ ស-២១ ដែលត្រូវបានថតភ្លាមៗ បន្ទាប់ពីការរកឃើញមន្ទីរសន្តិសុខស-២១ នេះ ដោយកងទ័ពវៀតណាម[1]។

២. ក្រុមមេធាវីការពារក្តីសូមបញ្ជាក់ថា ការស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញាមានរយៈពេលជិតមួយឆ្នាំ ហើយបន្ទាប់មកទៀត សហព្រះរាជអាជ្ញាបានចូលរួមក្នុងការស៊ើបអង្កេតអស់រយៈពេលចំនួនជាង ១០ខែ។ ហើយក្រោយពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួន នីតិវិធីដែលមានរយៈពេលជិតប្រាំមួយខែទៀតបានប្រព្រឹត្តទៅ មុននឹងសហព្រះរាជអាជ្ញាដាក់សំណើនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលបានទទួលបណ្តឹងអំពីរឿងក្តីនេះចាប់ពីពេលនេះតទៅ។

៣. ដោយហេតុដូច្នេះ ក្រុមមេធាវីការពារក្តីយល់ឃើញថា អំណះអំណាងរបស់សហព្រះរាជអាជ្ញាដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃភាពយឺតយ៉ាវក្នុងការដាក់ឯកសារទាំងនេះ គឺពិតជាមិនអាចទទួលយកបានជាដាច់ខាត។

៤. ដូច្នេះ នៅក្នុងស្ថានភាពនេះ ក្រុមមេធាវីការពារក្តីគ្រាន់តែស្នើទៅអង្គជំនុំជម្រះសាលាដំបូងឲ្យផាត់ឯកសារទាំងនេះចេញពីការជជែកដេញដោលតែប៉ុណ្ណោះ។

៥. ប្រសិនបើមិនអាចធ្វើទៅបាន ហើយអង្គជំនុំជម្រះសាលាដំបូងយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញានោះ ក្រុមមេធាវីការពារក្តីសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា ក្រុមមេធាវីការពារក្តីចាត់ទុកថា ខ្សែភាពយន្តទាំងនោះគឺជាការបំផ្លែងព័ត៌មានដ៏កំរោល ហើយក្រុម

[1] *សំណើរបស់សហព្រះរាជអាជ្ញាសំដៅដាក់ធាតុភស្តុតាងថ្មីៗ* ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ (ឯកសារជាភាសាបារាំងដែលបានជូនដំណឹងនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩) E5/10 ។

ES/10/1

[០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.០២)]

មេធាវីការពារក្តីសូមរក្សាសិទ្ធិពិនិត្យមើលបញ្ហានេះឡើងវិញ នៅក្នុងពេលសវនាការលើអង្គសេចក្តី។

## សូមរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | |
|---|---|---|
| សហមេធាវីការពារក្តី<br><br>លោក<br>**ការ សាវុត្ថ**<br><br>លោក<br>François Roux | ភ្នំពេញ | |
| ឈ្មោះ | ទីកន្លែង | ហត្ថលេខា |